ក

មាតិកា

I~ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

៣០-៤-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៤០៧/១៥៦ ស្តីពីការបញ្ចប់មុខតំណែងឯកឧត្តម **ចាន់ ហុង** ពីទីប្រឹក្សា ទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច របស់ឯកឧត្តម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី	៣៤១២
៣០-៤-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៤០៧/១៥៧ ស្តីពីការប្រោសព្រះរាជទាន នូវ គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តមចំនួន ០៣ រូប	៣៤១៣
៣០-៤-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៤០៧/១៥៨ ស្តីពីការតែងតាំង ឯកឧត្តម **ហួត ហាក់** ជាទីប្រឹក្សាផ្ទាល់ **សម្តេច ហេង សំរិន** ប្រធានរដ្ឋសភានីតិកាលទី ៣ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន	៣៤១៤

II~រាជរដ្ឋាភិបាល

អនុក្រឹត្យ

០២-៥-២០០៧	-អនុក្រឹត្យលេខ ៤១ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា	៣៤១៥
០៣-៥-២០០៧	-អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា	៣៤១៧
០២-៥-២០០៧	-អនុក្រឹត្យលេខ ៣៥១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៣៤១៩
០២-៥-២០០៧	-អនុក្រឹត្យលេខ ៣៥២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី	៣៤២០
០២-៥-២០០៧	-អនុក្រឹត្យលេខ ៣៥៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៣៤២១
០២-៥-២០០៧	-អនុក្រឹត្យលេខ ៣៥៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ	៣៤២៣
០២-៥-២០០៧	-អនុក្រឹត្យលេខ ៣៥៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៣៤២៥
០២-៥-២០០៧	-អនុក្រឹត្យលេខ ៣៥៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៣៤៣០
០២-៥-២០០៧	-អនុក្រឹត្យលេខ ៣៥៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៣៤៣២
០២-៥-២០០៧	-អនុក្រឹត្យលេខ ៣៥៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៣៤៣៣
០២-៥-២០០៧	-អនុក្រឹត្យលេខ ៣៥៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៣៤៣៤

០២-៥-២០០៧ -អនុក្រឹត្យលេខ ៣៦០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៤៣៥

III_ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៧-៤-២០០៧ -ប្រកាសលេខ ៣៨៤ សហវ.ប្រក ស្តីពីការកំណត់មូលដ្ឋានគិតអាករពិសេសលើទំនិញមួយចំនួនដែលផលិតក្នុងស្រុក ៣៤៣៧

១៩-៤-២០០៧ -សេចក្តីជូនដំណឹងលេខ ០០៩ សហវ.ឧហ ស្តីពីការផ្តល់វិញ្ញាបនប័ត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណប្រកបសេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុ ៣៤៣៩

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

៣០-៤-២០០៧ -ប្រកាសលេខ ៦០៦ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **រំលេច** " ស្ថិតនៅក្នុងឃុំ រំលេច ស្រុក ស៊ីធរកណ្តាល ខេត្ត ព្រៃវែង ៣៤៤០

៣០-៤-២០០៧ -ប្រកាសលេខ ៦០៧ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **មេបុណ្យ** " ស្ថិតនៅក្នុង ឃុំ មេបុណ្យ ស្រុក ព្រៃវែង ខេត្ត ព្រៃវែង ៣៤៤១

៣០-៤-២០០៧ -ប្រកាសលេខ ៦០៨ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ស្វាយបុព្រឹក្ស** " ស្ថិតនៅក្នុង ឃុំ ជាខ្លាង ស្រុក ព្រៃវែង ខេត្ត ព្រៃវែង ៣៤៤២

៣០-៤-២០០៧ -ប្រកាសលេខ ៦០៩ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ស្តី "ខ"** " ស្ថិតនៅក្នុងឃុំ ស្តី "ខ" ស្រុក បាភ្នំ ខេត្ត ព្រៃវែង ៣៤៤៣

៣០-៤-២០០៧ -ប្រកាសលេខ ៦១០ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ព្រែកដំ** " ស្ថិតនៅក្នុងឃុំ អ្នកលឿង ស្រុក ពាមរក៍ ខេត្ត ព្រៃវែង ៣៤៤៤

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៩៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ.អាយ.ត៊ី.អេស. ខបភើរេសិន (ខេមបូឌា)** ៣៤៤៥

១២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៩៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌី ធី ដាប់បែលយូ មេនេចមេន (ខេមបូឌា) ខូ អិលធីឌី** ៣៤៤៧

គ

១២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០២០២ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ក្លូននេចស្យូទ ជី គុំមែកស៍ (អូ កាំបូដហ្យ)** ៣៤៤៩

១២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០២០៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មោគនៈ** ៣៤៥១

១២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០២០៤ ពណ.នតកស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉េង លាង អ៊ីមផត អិចផត** ៣៤៥៣

១២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០២០៨ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វូ ហ្វូ អ៊ិនដាស ទ្រៀល ត្រេដ ខូ អិលធីឌី** ៣៤៥៥

១២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០២០៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មួន ឃួត** ៣៤៥៧

១២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០២១២ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ី ខេ អេស៊ា ប៉ាស៊ីហ្វិក** ៣៤៥៩

១៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០២១៧ ពណ.នតកស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(កម្ពុជា) អង្គរ ខូ អិលធីឌី** ៣៤៦១

១៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០២២០ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស៊ា ផាម** ៣៤៦៣

១៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០២២១ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សុវណ្ណភូមិ ត្រេន ស្ព័រថេសិន** ៣៤៦៥

១៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០២២២ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វ្រីន ដាយអឹម៉ិន អ៊ិនធើណេសិនណាល** ៣៤៦៧

១៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០២២៥ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) ឡុងធិន អ៊ិសស្ទេត ខូ អិលធីឌី** ៣៤៦៩

ព្រះរាជក្រឹត្យ

នស/រកត/០៤០៧/១៥៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម **ចាន់ ហុង** ពីទីប្រឹក្សា ទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច របស់ឯកឧត្តម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.០៧០៤.១៦៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៧

លេខ: ១៧៤៥ ច.ល
ដើម្បីថតចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែ០៥ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ចិនកេង

ព្រះរាជក្រឹត្យ

នស/រកត/០៤០៧/១៥៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់ព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ

១-ឯកឧត្តម នួម សុវត្ថិ

២-ឯកឧត្តម ស្រី ចំនួនី

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សរិទ្ធិ ចំពោះ

-ឯកឧត្តម ឡៀង វណ្ណជារ៉ុង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤/ល.០៧០៤.១៦៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៧

លេខ: ១៧៧/ច.ល
ជើងរៀងចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ... ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៧/១៦៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី៤ នីតិកាលទី៣ នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេច ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

<u>ត្រាស់បង្គាប់</u>

<u>មាត្រា១</u> : ត្រូវបានតែងតាំង ឯកឧត្តម **ឃួត ឃាត់** ជាទីប្រឹក្សាផ្ទាល់ **សម្តេច ហេង សំរិន** ប្រធានរដ្ឋសភានីតិកាលទី៣ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន។

<u>មាត្រា២</u> : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

<u>មាត្រា៣</u> : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣០.០៧០៤.១៦៨

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០០៧

លេខ ១៧៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ. ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃួន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧. ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤. ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ រៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ១០/នស/៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែល ប្រកាសអោយប្រើដោយ ព្រះរាជ ក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និង ប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃ មាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក.ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួល ដោយនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅ របស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ២.០០០.០០០.០០០ រៀល (ពីរពាន់លានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក)នៃខ្ទង់ចំណាយមិនទាន់បាន បែងចែក មកជំពូក ៦៥ (ឧបត្ថម្ភកធន និង ជំនួយសង្គម) ជូនក្រសួង សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា ២ : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះទៅ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ការចំណាយឧបត្ថម្ភដល់កាកបាទក្រហមកម្ពុជា ឆ្នាំ ២០០៧ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី០៤ ខែឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤២ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥. ចុះថ្ងៃ ទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/១២០២/០២០. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ១២០៦/០៣៥. ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និង ប្រកាសលេខ ១៤០១ សហវ.ប្រក. ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១ : ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១៥.០០០ លានរៀល (ដប់ប្រាំពាន់លានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក ជូនក្រសួងសុខាភិបាលសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ហើយឥណទាននេះត្រូវបានបែងចែកសំរាប់ជំពូក ៦០(ការទិញ) ចំនួន ២.១៩៣ លានរៀល និង ជំពូក ៦៥ (ឧបត្ថម្ភធន និង ជំនួយសង្គម) ចំនួន ១២.៨០៧ លានរៀល ។

មាត្រា២ : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទិញឱសថ និង បរិក្ខារពេទ្យបន្ថែមក្នុងឆ្នាំ ២០០៧ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៥១ អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៦៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនឧកញ៉ា **អ៊ុន យុទ្ធី** ប្រធានក្រុមហ៊ុនបូរីកម្មករ ដែលបានចូលរួមចំណែកកសាង និងជួយឧបត្ថម្ភដល់ដំណើរការមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី នៅតាមខេត្ត-ក្រុងមួយចំនួន ដើម្បីអោយស្ត្រីក្រីក្រនៅតាមជនបទមានមុខជំនាញច្បាស់លាស់ សំរាប់ប្រកបមុខរបរចិញ្ចឹមជីវិត ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៤

រាជធានីភ្នំពេញ ថ្ងៃទី ១៨ [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥៧ អនក្រ.តត

អនុក្រឹត្យ

ស្ដីពីការជូនមេដាយសហមេត្រី

១៣៥

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនឥស្សរជនជប៉ុន ចំនួន០២រូប ដែលមានគុណបំណាច់ ក្នុងការជួយឧបត្ថម្ភ និងជួយបណ្ដុះបណ្ដាលបច្ចេកទេស ទូរគមនាគមន៍ ដល់មន្ត្រីនៃក្រសួងប្រៃសណីយ៍ និងទូរគម នាគមន៍កម្ពុជា ដូចមានរាយនាមខាងក្រោម :-

ក_មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ :

-លោក NORIO WADA នាយក NTT

ខ_មេដាយសហមេត្រី ថ្នាក់ សេនា :

-លោក KAZUKI YAMASHITA ជំនាញការ (JICA) ប្រចាំការនៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ HHH

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចប្រការ ១ និង ប្រការ ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥៣ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងព័ត៌មាន

សម្រេច

មាត្រា១ : ត្រូវបានចំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន៤៣រូប នៃក្រសួងព័ត៌មាន ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចលើវិស័យព័ត៌មាន ដូចមានរាយនាមខាងក្រោម :-

ក_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

១-លោក ទូន សុផល អធិការ
២-លោកស្រី ហ្វី ផល្លា មន្ត្រី (សិល្បការិនី) RNK

ខ_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :

១-លោក ឈុំ សុជាតិ អគ្គនាយករង អគ្គនាយកដ្ឋាន វ/ប.ស/ទ
២-លោក ផុស សុវណ្ណ អគ្គនាយករង អគ្គនាយកដ្ឋាន វ/ប.ស/ទ
៣-លោក ជា សាមុង អគ្គនាយករង AKP
៤-លោក ឌួច សារ៉េត អគ្គនាយករង RNK
៥-លោក ឈាន លាង អគ្គនាយករង RNK
៦-លោក ជ័យ ធុណ្ណី អគ្គនាយករង RNK
៧-លោកស្រី ចំន្ទ ធី អគ្គនាយករង TVK
៨-លោក ឆន់ សារ៉ាត ប្រធានមន្ទីរ RNK
៩-លោក ស៊ិន សុយឿន ប្រធានមន្ទីរ TVK
១០-លោក ឆន់ សារ៉ឹម អនុប្រធាននាយកដ្ឋាន អគ្គនាយកដ្ឋាន វ/ប.ស/ទ
១១-លោក ឡើង សម្បត្តិ អនុប្រធាននាយកដ្ឋាន អគ្គនាយកដ្ឋាន វ/ប.ស/ទ
១២-លោក សោម ចូរ៉ា អនុប្រធាននាយកដ្ឋាន អគ្គនាយកដ្ឋាន វ/ប.ស/ទ

១៣-លោក	វ៉ាង សុខ	អនុប្រធាននាយកដ្ឋាន អគ្គនាយកដ្ឋាន វ/ប.ស/ទ
១៤-លោក	ឃឹម គឹមស៊ុន	អនុប្រធាននាយកដ្ឋាន អគ្គនាយកដ្ឋាន វ/ប.ស/ទ
១៥-លោក	ពេញ យ៉ាន	អនុប្រធាននាយកដ្ឋាន ទទួលខេត្ត-ក្រុង
១៦-លោក	សុខ សារឿន	អនុប្រធាននាយកដ្ឋាន RNK
១៧-លោក	អ៊ុំ ផន	អនុប្រធាននាយកដ្ឋាន TVK
១៨-លោកស្រី	សុន ម៉ារ៉ាដា	អនុប្រធាននាយកដ្ឋាន TVK
១៩-លោក	ជ័យ សោភា	អនុប្រធាននាយកដ្ឋាន TVK
២០-លោក	កេត ឈារ៉ាន	ប្រធានមន្ទីរព័ត៌មានខេត្តព្រៃវែង
២១-លោក	ឃឹម ញ៉ឹប	ប្រធានមន្ទីរព័ត៌មានខេត្តកណ្តាល
២២-លោក	ផាន់ វណ្ណសិទ្ធ	ប្រធានមន្ទីរព័ត៌មានខេត្តពោធិ៍សាត់
២៣-លោក	អេ សារុម	ប្រធានមន្ទីរព័ត៌មានខេត្តបាត់ដំបង
២៤-លោក	សេ ស៊ែ	ប្រធានមន្ទីរព័ត៌មានខេត្តកំពត
២៥-លោក	កែវ សាមឿន	ប្រធានមន្ទីរព័ត៌មានខេត្តស្វាយរៀង
២៦-លោក	ម៉ម ម៉ាលី	ប្រធានមន្ទីរព័ត៌មានក្រុងព្រះសីហនុ
២៧-លោក	ម៉ាន់ សារ៉ាន់	ប្រធានមន្ទីរព័ត៌មានខេត្តកំពង់ធំ
២៨-លោក	រ៉ាត់ សោភា	ប្រធានមន្ទីរព័ត៌មានខេត្តព្រះវិហារ
២៩-លោក	ម៉ុក ថារី	ប្រធានមន្ទីរព័ត៌មានខេត្តស្ទឹងត្រែង
៣០-លោក	កែវ សេដ្ឋា	ប្រធានមន្ទីរព័ត៌មានខេត្តកោះកុង
៣១-លោក	អ៊ុំ ហឿន	ប្រធានមន្ទីរព័ត៌មានខេត្តសៀមរាប
៣២-លោក	មុត សារិន	ប្រធានមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យ
៣៣-លោក	សំ ពិសី	ប្រធានមន្ទីរព័ត៌មានខេត្តកំពង់ស្ពឺ
៣៤-លោក	ឃឹម ម៉ុនថន	ប្រធានមន្ទីរព័ត៌មានខេត្តឧត្តរមានជ័យ
៣៥-លោក	គឹម ធាតូ	ប្រធានមន្ទីរព័ត៌មានខេត្តក្រចេះ
៣៦-លោក	យូ ចន្ទីរ	ប្រធានមន្ទីរព័ត៌មានខេត្តមណ្ឌលគិរី
៣៧-លោក	អៀង សិរៈ	ប្រធានមន្ទីរព័ត៌មានខេត្តរតនគិរី
៣៨-លោក	គង់ ឌួង	ប្រធានមន្ទីរព័ត៌មានក្រុងប៉ៃលិន
៣៩-លោក	អ៊ុក សាខន	ប្រធានមន្ទីរព័ត៌មានក្រុងកែប
៤០-លោក	ម៉ម ឈឿម	ប្រធានមន្ទីរព័ត៌មានខេត្តកំពង់ឆ្នាំង
៤១-លោក	កែវ ពេជ្រនិមល	ប្រធានមន្ទីរព័ត៌មានខេត្តតាកែវ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

[illegible] សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៥៤ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងព័ត៌មាន

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន១៧២រូប នៃក្រសួងព័ត៌មាន ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច លើវិស័យព័ត៌មាន ដូចមានរាយនាមខាងក្រោម :-

ក_មេដាយមាសការងារ :

១-លោក	**ហាស់ សំអាត**	អគ្គនាយករង អគ្គនាយកដ្ឋាន វ/បា.ស/ទ
២-លោក	**សោម ឫទ្ធី**	អគ្គនាយករង AKP
៣-លោក	**ឈី ម៉ាន់ហួង**	អគ្គនាយករង អគ្គនាយកដ្ឋាន វ/បា.ស/ទ
៤-លោក	**ម៉ុន ហៀម**	អគ្គនាយករង RNK
៥-លោក	**មៀច ចន្ទសុវណ្ណ**	អនុប្រធាននាយកដ្ឋាន អគ្គនាយកដ្ឋាន វ/បា.ស/ទ
៦-លោក	**គង សុវណ្ណ**	អនុប្រធាននាយកដ្ឋាន អគ្គនាយកដ្ឋាន វ/បា.ស/ទ
៧-លោក	**ផាន់ សារិន**	អនុប្រធាននាយកដ្ឋាន អគ្គនាយកដ្ឋាន វ/បា.ស/ទ
៨-លោក	**សាន ពុទ្ធារី**	អនុប្រធាននាយកដ្ឋាន អគ្គនាយកដ្ឋាន វ/បា.ស/ទ
៩-លោក	**ឈឿន ណារិទ្ធ**	អធិការរង អគ្គនាយកដ្ឋាន វ/បា.ស/ទ
១០-លោក	**ឆូ ពៅ**	អនុប្រធាននាយកដ្ឋាន AKP
១១-លោក	**ជា ផារិទ្ធ**	អនុប្រធាននាយកដ្ឋាន AKP
១២-លោក	**ខែម សង្វាត**	អនុប្រធាននាយកដ្ឋាន AKP
១៣-លោក	**សូ វណ្ណដេត**	អនុប្រធាននាយកដ្ឋាន AKP
១៤-លោក	**ទិត ម៉ុនសោខ**	អនុប្រធាននាយកដ្ឋាន RNK

១៥-លោកស្រី រស់ ភគណ្ឌារី អនុប្រធាននាយកដ្ឋាន RNK
១៦-លោក ខ៊ែន សៅម៉ូរ៉ាក្ស អនុប្រធាននាយកដ្ឋាន RNK
១៧-លោក សោម សាត អនុប្រធាននាយកដ្ឋាន RNK
១៨-លោកស្រី ម៉ុក គីមសួរ អនុប្រធាននាយកដ្ឋាន RNK
១៩-លោក ឆឹង គីមស្រេង អនុប្រធាននាយកដ្ឋាន RNK
២០-លោក ជាំ សុខេន អនុប្រធាននាយកដ្ឋាន TVK
២១-លោកស្រី យក់ សារ៉េន ប្រធានមន្ទីរព័ត៌មាន ខេត្តកំពង់ចាម
២២-លោក ឡាយ ចេងលៀង អនុប្រធានមន្ទីរព័ត៌មាន ខេត្តពោធិ៍សាត់
២៣-លោក ឡុង ឈុនឡៃ អនុប្រធានមន្ទីរព័ត៌មាន ខេត្តកំពង់ឆ្នាំង
២៤-លោក ស្រេង ដេត ប្រធានការិយាល័យរដ្ឋបាលវិទ្យុជាតិ
២៥-លោក ឈឹម ឫទ្ធី ប្រធានការិយាល័យទូរទស្សន៍ជាតិ
២៦-លោកស្រី ឡាយ លក្ស្មី ប្រធានការិយាល័យទូរទស្សន៍ជាតិ
២៧-លោក ម៉ែរ សុខន ប្រធានការិយាល័យមន្ទីរព័ត៌មានខេត្តកំពង់ស្ពឺ

ខ-មេដាយប្រាក់ការងារ :

១-លោក ឈុន ម៉ិនសុង អនុប្រធាននាយកដ្ឋាន អគ្គនាយកដ្ឋាន រ/ប.ស/ទ
២-លោក នុយ សុខចេង អនុប្រធាននាយកដ្ឋាន អគ្គនាយកដ្ឋាន រ/ប.ស/ទ
៣-លោក យ៉ែម ណយ អនុប្រធាននាយកដ្ឋាន អគ្គនាយកដ្ឋាន រ/ប.ស/ទ
៤-លោក ម៉ុន ម៉ិនសុង អនុប្រធាននាយកដ្ឋាន អគ្គនាយកដ្ឋាន រ/ប.ស/ទ
៥-លោក នង ស៊ីណា អនុប្រធាននាយកដ្ឋាន អគ្គនាយកដ្ឋាន រ/ប.ស/ទ
៦-លោក ចាន់ សម្បត្តិ អនុប្រធាននាយកដ្ឋាន AKP
៧-លោក អ៊ុក សាផាន អនុប្រធាននាយកដ្ឋាន AKP
៨-លោក ឈី ចន្ថា អនុប្រធាននាយកដ្ឋាន RNK
៩-លោក ជៀង យ៉ារ៉ែត អនុប្រធាននាយកដ្ឋាន RNK
១០-លោក ចៅ ស្រេង អនុប្រធានមន្ទីរព័ត៌មានក្រុងភ្នំពេញ
១១-លោក នង ស៊ីថន អនុប្រធានមន្ទីរព័ត៌មាន ខេត្តព្រះវិហារ
១២-លោកស្រី ណៃ ធីតា អនុប្រធានមន្ទីរព័ត៌មាន ខេត្តក្រចេះ
១៣-លោក សៀង វណ្ណថារ៉ា ប្រធានការិយាល័យ អគ្គនាយកដ្ឋាន រ/ប.ស/ទ
១៤-លោក នួន សំអាត ប្រធានការិយាល័យ អគ្គនាយកដ្ឋាន រ/ប.ស/ទ
១៥-លោក អ៊ួន សាយ៉ុន ប្រធានការិយាល័យ អគ្គនាយកដ្ឋាន រ/ប.ស/ទ
១៦-លោក គ្រី ហុក ប្រធានការិយាល័យ AKP
១៧-លោក ពេជ្រ ណារិទ្ធ ប្រធានការិយាល័យ AKP
១៨-លោក ឈុប ដារ៉ា ប្រធានការិយាល័យ AKP
១៩-លោក អន ខេមរិទ្ធ ប្រធានការិយាល័យ AKP
២០-លោក ឈួរ តារា ប្រធានការិយាល័យ RNK
២១-លោក រិន ឆាយ ប្រធានការិយាល័យ RNK
២២-លោក ឈី គៀម ប្រធានការិយាល័យ មន្ទីរព័ត៌មានក្រុងភ្នំពេញ
២៣-លោក ធីក សាធឿន ប្រធានការិយាល័យ មន្ទីរព័ត៌មានខេត្តបាត់ដំបង
២៤-លោក យី សារ៉ាយ ប្រធានការិយាល័យ មន្ទីរព័ត៌មានខេត្តតាកែវ

២៥-លោកស្រី	គង់	សុខុម	អនុប្រធានការិយាល័យ មន្ទីរព័ត៌មានខេត្តកំពង់ឆ្នាំង
២៦-លោក	ឃួន	សារឿន	អនុប្រធានការិយាល័យ អគ្គនាយកដ្ឋាន វ/ធា.ស/ទ
២៧-លោកស្រី	ឌិត្យ	ភល្យាណី	អនុប្រធានការិយាល័យ អគ្គនាយកដ្ឋាន វ/ធា.ស/ទ
២៨-លោក	អ៊ិច	ស៊ីថា	អនុប្រធានការិយាល័យ អគ្គនាយកដ្ឋាន វ/ធា.ស/ទ
២៩-លោកស្រី	ហួង	លក្ស្មី	អនុប្រធានការិយាល័យ AKP
៣០-លោក	ស៊ុម	វណ្ណា	អនុប្រធានការិយាល័យ AKP
៣១-លោកស្រី	នី	គីមឡា	អនុប្រធានការិយាល័យ AKP
៣២-លោកស្រី	រស់	សារួន	អនុប្រធានការិយាល័យ AKP
៣៣-លោក	សាន	សុលី	អនុប្រធានការិយាល័យ AKP
៣៤-លោក	នី	សំអុល	អនុប្រធានការិយាល័យ AKP
៣៥-លោក	ម៉ក់	ផលឡៃ	អនុប្រធានការិយាល័យ RNK
៣៦-លោកស្រី	នួន	បូរ	អនុប្រធានការិយាល័យ RNK
៣៧-លោក	អន	ឌុក	អនុប្រធានការិយាល័យ RNK
៣៨-លោកស្រី	កែវ	សុខណា	អនុប្រធានការិយាល័យ TVK
៣៩-លោក	ហែម	បូរិន	អនុប្រធានការិយាល័យ TVK
៤០-លោកស្រី	សូលី	វណ្ណនី	អនុប្រធានការិយាល័យ មន្ទីរព័ត៌មាន ខេត្តកំពង់ស្ពឺ
៤១-លោក	យូ	ឆន	អនុប្រធានការិយាល័យ មន្ទីរព័ត៌មាន ខេត្តកំពង់ស្ពឺ
៤២-លោក	ឈឿន	ស៊ីន	មន្ត្រី RNK
៤៣-លោក	សឿ	សាវុធ	មន្ត្រី RNK
៤៤-លោក	ថុក	អ៊ូច	មន្ត្រី RNK
៤៥-លោកស្រី	រស់	គន្ធា	មន្ត្រី RNK
៤៦-លោកស្រី	ចាន់	កែវ	មន្ត្រី TVK
៤៧-លោកស្រី	វង្ស	ពៅ	មន្ត្រី TVK

គ-មេដាយសេរីវឌ្ឍការងារ :

១-លោក	កែវ	ចំនួនរ៉ា	អនុប្រធាននាយកដ្ឋាន AKP
២-លោក	ឡឹក	សារឿន	អនុប្រធាននាយកដ្ឋាន RNK
៣-លោក	គី	ម៉ាលី	អនុប្រធាននាយកដ្ឋាន RNK
៤-លោក	ចាន់	សូរ	ប្រធានការិយាល័យ AKP
៥-លោក	ហ៊ុច	ស៊ា	ប្រធានការិយាល័យ RNK
៦-លោកស្រី	សុខ	សុវណ្ណារី	ប្រធានការិយាល័យ TVK
៧-លោក	ជា	គង់	អនុប្រធានមន្ទីរព័ត៌មានក្រុងភ្នំពេញ
៨-លោក	ហួង	ពៅ	អនុប្រធានមន្ទីរព័ត៌មានខេត្តកំពង់ស្ពឺ
៩-លោកស្រី	យ៉ាន់	សុខុម	អនុប្រធានមន្ទីរព័ត៌មានខេត្តស្ទឹងត្រែង
១០-លោក	សេង	សំណាង	អនុប្រធានការិយាល័យ AKP
១១-លោកស្រី	ម៉ែន	សុផន	អនុប្រធានការិយាល័យ AKP
១២-លោកស្រី	ជាស	និដ្ឋា	អនុប្រធានការិយាល័យ AKP
១៣-លោក	ម៉ៅ	បូរីរដ្ឋ	អនុប្រធានការិយាល័យ AKP
១៤-លោកស្រី	ផ្លាង	សំអាង	អនុប្រធានការិយាល័យ RNK

១៥-លោកស្រី	អ៊ុខ	គឹមហ៊ីន	អនុប្រធានការិយាល័យ RNK
១៦-លោក	ឈន	ដារ៉ាវិចិត្រ	អនុប្រធានការិយាល័យ TVK
១៧-លោក	ឃួន	[illegible]	អនុប្រធានការិយាល័យ TVK
១៨-លោក	សន	សារ៉ាវុធ	អនុប្រធានការិយាល័យ TVK
១៩-លោក	ឈុយ	សំអាត	អនុប្រធានការិយាល័យ TVK
២០-លោក	ម៉េន	ម៉ិច	អនុប្រធានការិយាល័យ TVK
២១-លោកស្រី	ឡូ	ផល្លា	អនុប្រធានការិយាល័យ TVK
២២-លោក	ម៉េន	វណ្ណថន	ប្រធានការិយាល័យវិទ្យុ ខេត្តព្រៃវែង
២៣-លោក	ស	ស៊ុណា	ប្រធានការិយាល័យរដ្ឋបាល ខេត្តកំពង់ចាម
២៤-លោក	សុខ	វណ្ណនី	អនុប្រធានការិយាល័យ ទូរទស្សន៍រាជធានីភ្នំពេញ
២៥-លោក	ឆាំត	ពណ្ណរាយ	អនុប្រធានការិយាល័យវិទ្យុ ខេត្តកំពង់ធំ
២៦-លោក	អ៊ុច	ចាន់ធារិទ្ធ	អនុប្រធានការិយាល័យវិទ្យុ ខេត្តពោធិ៍សាត់
២៧-លោក	គ្រៀល	សុគឿន	អនុប្រធានការិយាល័យរដ្ឋបាលក្រុងព្រះសីហនុ
២៨-លោកស្រី	ស៊ុយ	វ៉ាន់នី	អនុប្រធានការិយាល័យរដ្ឋបាលខេត្តក្រចេះ
២៩-លោក	ចាន់	សុភាព	ប្រធានការិយាល័យ ព័ត៌មានខ័ណ្ឌប្រាំពីរមករា
៣០-លោក	អ៊ំ	ណារិទ្ធ	ប្រធានការិយាល័យ ព័ត៌មាន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល
៣១-លោក	គឹម	ផូយ	ប្រធានការិយាល័យ ព័ត៌មាន ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល
៣២-លោក	ម៉ុក	សុមុន្នី	ប្រធានការិយាល័យ ព័ត៌មាន ស្រុកលើកដែក ខេត្តកណ្តាល
៣៣-លោក	ហួន	សំអាត	ប្រធានការិយាល័យ ព័ត៌មាន ស្រុកមុខកំពូល ខេត្តកណ្តាល
៣៤-លោក	ម៉ុក	ម៉ិច	ប្រធានការិយាល័យ ព័ត៌មាន ស្រុកអង្គស្នួល ខេត្តកណ្តាល
៣៥-លោក	សួស	ម៉ុនធួន	ប្រធានការិយាល័យ ព័ត៌មាន ស្រុកកងមាស ខេត្តកំពង់ចាម
៣៦-លោក	ភខ	គឿន	ប្រធានការិយាល័យ ព័ត៌មាន ស្រុកកំពង់សៀម ខេត្តកំពង់ចាម
៣៧-លោក	សែម	សៅនី	ប្រធានការិយាល័យ ព័ត៌មាន ស្រុកចំការលើ ខេត្តកំពង់ចាម
៣៨-លោក	សន	គន្ធា	ប្រធានការិយាល័យ ព័ត៌មាន ស្រុកកំពង់ចាម ខេត្តកំពង់ចាម
៣៩-លោក	ឈួន	សួស្តី	ប្រធានការិយាល័យ ព័ត៌មាន ស្រុកកណ្តៀង ខេត្តពោធិ៍សាត់
៤០-លោក	សុខ	លីម	ប្រធានការិយាល័យ ព័ត៌មាន ស្រុក ខេត្តបាត់ដំបង
៤១-លោក	ប៊ិ	សយ	ប្រធានការិយាល័យ ព័ត៌មាន ស្រុក ខេត្តបាត់ដំបង
៤២-លោក	គឹម	អឿន	ប្រធានការិយាល័យ ព័ត៌មាន ស្រុក ខេត្តបាត់ដំបង
៤៣-លោក	ភខ	សារី	ប្រធានការិយាល័យ ព័ត៌មាន ស្រុក ខេត្តបាត់ដំបង
៤៤-លោក	អ៊ិន	សាមន	ប្រធានការិយាល័យ ព័ត៌មាន ស្រុក ខេត្តស្វាយរៀង
៤៥-លោក	សុក	សំអន	ប្រធានការិយាល័យ ព័ត៌មាន ស្រុក ខេត្តស្វាយរៀង
៤៦-លោក	ឃ្លាំខ	ជាខ	ប្រធានការិយាល័យ ព័ត៌មាន ខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ
៤៧-លោក	ឆ	គុយ	ប្រធានការិយាល័យ ព័ត៌មាន ស្រុកពួក ខេត្តសៀមរាប
៤៨-លោក	យូ	ថៃ	ប្រធានការិយាល័យ ព័ត៌មាន ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ
៤៩-លោកស្រី	កែម	ណារី	ប្រធានការិយាល័យ ព័ត៌មាន ស្តីទី ស្រុក ខេត្តកំពត
៥០-លោក	ឆាយ	ម៉ារិន	ប្រធានការិយាល័យ ព័ត៌មាន ស្រុក បានលុងខេត្តរតនគិរី
៥១-លោក	ម៉ុន	ទឹម	ប្រធានការិយាល័យ ព័ត៌មាន ស្រុកគីរីវង់ ខេត្តតាកែវ
៥២-លោក	គោគ	ផល្លា	អនុប្រធានការិយាល័យ ព័ត៌មាន ស្រុកគីរីវង់ ខេត្តតាកែវ
៥៣-លោក	អ៊ុំ	ឡូ	អនុប្រធានការិយាល័យ ព័ត៌មាន ស្រុក ខេត្តកំពង់ឆ្នាំង

៥៤-លោក	វុំឡ	សេន	អនុប្រធានការិយាល័យ ព័ត៌មាន ស្រុក ខេត្តស្វាយរៀង
៥៥-លោក	អ៊ិច	សារ៉េច	អនុប្រធានការិយាល័យ មន្ទីរព័ត៌មាន ក្រុងប៉ៃលិន
៥៦-លោក	កែវ	គា	មន្ត្រីក្រមការ ខេត្តព្រៃវែង
៥៧-លោក	ម៉េង	ឃុត	មន្ត្រី អគ្គនាយកដ្ឋានវ/បា.ស/ទ
៥៨-លោក	ម៉េន	រស្មី	មន្ត្រី អគ្គនាយកដ្ឋានវ/បា.ស/ទ
៥៩-លោកស្រី	យិន	ស៊ីថា	មន្ត្រី អគ្គនាយកដ្ឋានវ/បា.ស/ទ
៦០-លោក	ឃុន	ទន	មន្ត្រី AKP
៦១-លោក	ឆិត	ស្រី	មន្ត្រី AKP
៦២-លោក	កែវ	សំអឿន	មន្ត្រី AKP
៦៣-លោក	ឡឿន	ពេន	មន្ត្រី AKP
៦៤-លោក	សួស	សារិត	មន្ត្រី AKP
៦៥-លោកស្រី	អ៊ីង	សុម៉ាលី	មន្ត្រី RNK
៦៦-លោកស្រី	ម៉ុំ	សារ៉េន	មន្ត្រី RNK
៦៧-លោកស្រី	សេង	ស៊ីណា	មន្ត្រី RNK
៦៨-លោកស្រី	ស៊ិន	នារី	មន្ត្រី RNK
៦៩-លោក	ឆួន	ភ្លុក	មន្ត្រី RNK
៧០-លោក	ម៉ិច	អឿង	មន្ត្រី RNK
៧១-លោក	វណ្ណ	សំបូរ	មន្ត្រី RNK
៧២-លោក	ជុំ	ម៉ុន	មន្ត្រី TVK
៧៣-លោកស្រី	ឈុំ	ចាន់នី	មន្ត្រី TVK
៧៤-លោកស្រី	សារិន	ច័ន្ទមុន្នី	មន្ត្រី TVK
៧៥-លោកស្រី	ឆេព	គីមស្រ៊ិន	មន្ត្រី TVK
៧៦-លោកស្រី	សារី	បុស្សសុគុណ	មន្ត្រី TVK
៧៧-លោក	គីម	សារឿន	មន្ត្រី TVK
៧៨-លោក	ជា	ផានិត	មន្ត្រី TVK
៧៩-លោក	ស៊ុយ	សុធា	មន្ត្រី TVK
៨០-លោក	សំរិទ្ធ	សុធី	មន្ត្រីមន្ទីរព័ត៌មានក្រុងភ្នំពេញ
៨១-លោក	ស៊ិន	សុភី	មន្ត្រីមន្ទីរព័ត៌មានក្រុងភ្នំពេញ
៨២-លោក	សុខ	ខេង	មន្ត្រីមន្ទីរព័ត៌មានក្រុងភ្នំពេញ
៨៣-លោក	យី	យ៉ារ៉េត	មន្ត្រីមន្ទីរព័ត៌មាន ខេត្តព្រៃវែង
៨៤-លោក	ម៉េន	ម៉ុនឆន	មន្ត្រីមន្ទីរព័ត៌មាន ខេត្តព្រៃវែង
៨៥-លោក	គង់	គីមឈន	មន្ត្រីមន្ទីរព័ត៌មាន ខេត្តព្រៃវែង
៨៦-លោក	កែវ	ផាត	មន្ត្រីមន្ទីរព័ត៌មាន ខេត្តព្រៃវែង
៨៧-លោក	ខៀវ	សាមេត	មន្ត្រីមន្ទីរព័ត៌មាន ខេត្តព្រៃវែង
៨៨-លោក	អ៊ុម	ញឹប	មន្ត្រីមន្ទីរព័ត៌មាន ខេត្តកំពង់ធំ
៨៩-លោក	អាំ	សុទ្ធារិន	មន្ត្រីមន្ទីរព័ត៌មាន ខេត្តកំពង់ធំ
៩០-លោក	ឡុំ	សារីម	មន្ត្រីមន្ទីរព័ត៌មាន ខេត្តបាត់ដំបង
៩១-លោក	ឌី	សុខ	មន្ត្រីមន្ទីរព័ត៌មាន ខេត្តកំពត
៩២-លោក	អ៊ុំ	សារឿន	មន្ត្រីមន្ទីរព័ត៌មាន ខេត្តកំពត

៩៣-លោក	ម៉េង	ឧដ្ឋារ	មន្ត្រីមន្ទីរព័ត៌មាន ខេត្តកំពត
៩៤-លោក	ម៉ៅ	សួម	មន្ត្រីមន្ទីរព័ត៌មាន ខេត្តសៀមរាប
៩៥-លោក	ចិក	ម៉ៅ	មន្ត្រីមន្ទីរព័ត៌មាន ខេត្តបន្ទាយមានជ័យ
៩៦-លោក	ចក់	ម៉ិនលី	មន្ត្រីមន្ទីរព័ត៌មាន ខេត្តកំពង់ស្ពឺ
៩៧-លោក	ទួច	ពឿន	មន្ត្រីមន្ទីរព័ត៌មាន ក្រុងប៉ៃលិន
៩៨-លោក	ខឹម	ឡុច	មន្ត្រីមន្ទីរព័ត៌មាន ខេត្តសៀមរាប

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :
ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចមាត្រា ១ និង មាត្រា ២
រាជកិច្ច
ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥៥ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

ជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **SHIGETA YASUMITSU** ដែលបានឧបត្ថម្ភថវិកាតាមរយៈអង្គការ JHP មានទឹកប្រាក់ចំនួន ៤៥.០០០ ដុល្លារអាមេរិក សំរាប់កសាងអគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ បំពាក់ដោយសម្ភារៈ តុ កៅអី និង បង្គន់អនាម័យ ០១ខ្នង មាន ០៣ បន្ទប់ នៅសាលាបឋមសិក្សាកំពង់ក្របី ក្នុងឃុំព្រែកអាជី ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។ MR

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

ការ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានចំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេនចំពោះមន្ត្រីសង្ឃ ចំនួន២៦អង្គ គង់នៅស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ដែលមានស្នាព្រះហស្តល្អ ក្នុងការដឹកនាំ កសាងសមិទ្ធផលផ្សេងៗ ក្នុងព្រះពុទ្ធសាសនា និង សង្គម ដូចមានរាយព្រះនាមខាងក្រោម :-

ក_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-ព្រះសាតនវង្ស	**យិត សុខា**	រាជាគណៈថ្នាក់កិត្តិយស និងជាព្រះចៅអធិការវត្តទីបញ្ញារាម ឃុំកោះពីរ
២-ព្រះឧត្តមសីលញ្ញាណ	**ស្រុយ ផល្លី**	រាជាគណៈថ្នាក់កិត្តិយស និង ជាព្រះចៅអធិការវត្តនាគវ៉ន ឃុំកាខ្សរ
៣-ព្រះធម្មចរិយាមុនី	**សោម ចន់ថេង**	រាជាគណៈថ្នាក់កិត្តិយស និង ជាព្រះចៅអធិការវត្តវេឡុវតនារាម ឫស្សីកែវ ឃុំក្រូចឆ្មារ
៤-ព្រះវិនយសត្ថា	**គេច ហៃរ**	រាជាគណៈថ្នាក់កិត្តិយស និងជាព្រះចៅអធិការវត្តអម្ពវ៉ន ឃុំជីទីក

ខ_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សរិទ្ធិ :

១-ព្រះតេជគុណ	**សេង បូរិន**	ព្រះចៅអធិការវត្តចន្ទគាមទី ឃុំជីទីក
២-ព្រះតេជគុណ	**នន ចាយ**	ព្រះចៅអធិការវត្តហ្លួង ឃុំកាខ្សរ
៣-ព្រះតេជគុណ	**ស្រួយ គីមហេង**	ព្រះចៅអធិការវត្តនិគ្រោធារាម ឃុំប៉ើស ២
៤-ព្រះតេជគុណ	**ចាន់ ខឿន**	ព្រះចៅអធិការវត្តពោធិសាល ឃុំប៉ើស ២
៥-ព្រះតេជគុណ	**ហេង រតនា**	ព្រះចៅអធិការវត្តឥន្ទកោសិយ ឃុំស្វាយឃ្លាំង
៦-ព្រះតេជគុណ	**ឆាត់ នីន**	ព្រះចៅអធិការវត្តបទុមវតី ឃុំស្វាយឃ្លាំង

៧-ព្រះតេជគុណ	រាម សុវណ្ណ	ព្រះចៅអធិការវត្តបទុមកេសរ ឃុំស្វាយឃ្លាំង
៨-ព្រះតេជគុណ	ឌី សេងឌឿន	ព្រះចៅអធិការវត្តពោធិព្រឹក្ស ឃុំក្រូចឆ្មារ
៩-ព្រះតេជគុណ	គន ចាន់ថន	ព្រះចៅអធិការវត្តខ្សាច់ប្រឆេះ ឃុំក្រូចឆ្មារ
១០-ព្រះតេជគុណ	ឆាំង ថេស	ព្រះចៅអធិការវត្តទ្រា ឃុំទ្រា
១១-ព្រះតេជគុណ	ឧច រ៉ុន	ព្រះចៅអធិការវត្តខទិរារាម ឃុំព្រែកអាជី
១២-ព្រះតេជគុណ	ស៊ឹង ថាន់នី	ព្រះចៅអធិការវត្តតាលវនារាម ឃុំព្រែកអាជី
១៣-ព្រះតេជគុណ	ថុន សុខ	ព្រះចៅអធិការវត្តធម្មិស្សរារាម ឃុំព្រែកអាជី
១៤-ព្រះតេជគុណ	ឈិន ម៉ៅ	ព្រះចៅអធិការវត្តសាលបុប្ផារាម ឃុំកំពង់ទ្រាស
១៥-ព្រះតេជគុណ	ខេង ឈីធី	ព្រះចៅអធិការវត្តបន្ទាយជ័យមង្គល ឃុំកំពង់ទ្រាស
១៦-ព្រះតេជគុណ	ឌី សុខុម	ព្រះចៅអធិការវត្តទីបរតនសោភ័ណ ឃុំកោះពីរ
១៧-ព្រះតេជគុណ	ឈិន យ៉ាន់	ព្រះចៅអធិការវត្ត វេឡុវនារាម ឃុំកោះពីរ
១៨-ព្រះតេជគុណ	ឃួយ អ៊ាង	ព្រះចៅអធិការវត្តឈូក ឃុំឈូក
១៩-ព្រះតេជគុណ	ម៉ក់ ម៉ិន	ព្រះចៅអធិការវត្តជើងច្រង់ ឃុំទួលស្នួល
២០-ព្រះតេជគុណ	យ៉ាន ជ្រួន	ព្រះចៅអធិការវត្តគិរីមង្គល ឃុំទួលស្នួល
២១-ព្រះតេជគុណ	ជា ចិន្ត្រា	ព្រះចៅអធិការវត្តមង្គលវ័ន្ត ឃុំទួលស្នួល
២២-ព្រះតេជគុណ	ឈឹម ស៊ាន	ព្រះចៅអធិការវត្តរស្មីគិរី ឃុំទួលស្នួល

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។ *MR+*

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

__កន្លែងទទួល :__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះសង្ឃ ០១អង្គ និងជូនសប្បុរសជន ០៣រូប ដែលបានឧបត្ថម្ភថវិកាជួយកសាងព្រះវិហារ និងសមិទ្ធផលផ្សេងៗទៀត នៅ ***វត្តបំពេញកុសល*** ក្នុងឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

១-ព្រះតេជគុណ	**ឡាច**	**ឈាន**	ចៅអធិការ ***វត្តបំពេញកុសល***	បច្ច័យចំនួន ១៥៥.៩៥០ ដុល្លារ
២-ឧបាសក	**នៅ**	**នួន**	សប្បុរសជននៅខណ្ឌដង្កោរាជធានីភ្នំពេញ	ថវិកាចំនួន ១១.៥០០ ដុល្លារ
៣-ឧបាសក	**អ៊ុច**	**ពុំ**	អាចារ្យវត្តបំពេញកុសល	ថវិកាចំនួន ៥២.៥០០ ដុល្លារ
៤-ឧបាសក	**មោ**	**ថន**	គណៈកម្មការវត្តបំពេញកុសល	ថវិកាចំនួន ៥២.៥០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៥៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

១៧៤

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះសង្ឃ ០១អង្គ និង ជូនសប្បុរសជន ០២រូប ដែលបានបរិច្ចាគធនធានជួយកសាង ផ្លូវថ្នល់ ព្រះវិហារ ខ្លោងទ្វារ និងសមិទ្ធផលផ្សេងៗទៀត នៅវត្តភ្នំតាម៉ៅ ក្នុងឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

១-ព្រះតេជគុណ **សៅ សារុន**	ចៅអធិការ *វត្តភ្នំតាម៉ៅ*	បច្ច័យចំនួន ១១.២៥០ ដុល្លារ
២-លោកជំទាវ **ស្នូ គែច**	ភរិយាឯកឧត្តម **ចំន្ទ សារុន**	ថវិកាចំនួន ១៧.០០០ ដុល្លារ
៣-មហាឧបាសិកា **លី សេងហេង**	សប្បុរសជនខ្មែរនៅប្រទេសបារាំង	ថវិកាចំនួន ១២.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន Sister **DENISE** ប្រធានអង្គការ **JSC** ដែលបានឧបត្ថម្ភថវិកា ចំនួន ១៦.១៣៣ ដុល្លារ សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង និង បង្គន់អនាម័យ ០១ខ្នង នៅសាលាបឋមសិក្សាស្ទួនពេជ្រ ក្នុងឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៦០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន ២២រូប ដែលបានបរិច្ចាគធនធានជួយកសាងអគារមន្ទីរពេទ្យបង្អែកព្រៃកប្បាស ០១ខ្នង ព្រមទាំងសាលារៀន និងសមិទ្ធផលផ្សេងៗទៀត នៅ ***វត្តប្រាសាទមង្គល*** និង ***វត្តប្រាសាទនាងខ្មៅ*** ក្នុងស្រុកព្រៃកប្បាស និង ស្រុកសំរោង ខេត្តតាកែវ ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

ក. មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ	**អ៊ុន សារឿន**	ចៅអធិការ ***វត្តប្រាសាទមង្គល***	បច្ច័យចំនួន ១២.៣០០ ដុល្លារ
២-ព្រះតេជគុណ	**សំ ឡាំង**	ចៅអធិការ ***វត្តប្រាសាទនាងខ្មៅ***	បច្ច័យចំនួន ១៣.២០០ ដុល្លារ
៣-លោក	**ឈៀង សែ**	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១៣.៥០០ ដុល្លារ
៤-ឧបាសិកា	**នួន ទៀក**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន១២.២៧០ ដុល្លារ
៥-ឧបាសិកា	**ខូយ សៀ**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១២.១៩៥ ដុល្លារ
៦-ឧបាសិកា	**ខូយ ឈៀង**	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១២.០០០ ដុល្លារ
៧-ឧបាសិកា	**អ៊ូ សយ**	សប្បុរសជននៅទីក្រុងភ្នំពេញ	ថវិកាចំនួន ១២.៣៥០ ដុល្លារ
៨-លោក	**ង៉ែត ចិល**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១៣.០០០ ដុល្លារ
៩-ឧបាសិកា	**អៀង គឹមហួយ**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១៦.១៦៥ ដុល្លារ
១០-ឧបាសិកា	**ឧត្តមារៈពេជ អូន**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៥២.៣០០ ដុល្លារ
១១-ឧបាសិកា	**អៀប ឆៃហុង**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១២.២០០ ដុល្លារ
១២-ឧបាសិកា	**យិន លឹម**	សប្បុរសជននៅទីក្រុងភ្នំពេញ	ថវិកាចំនួន ២៥.១០០ ដុល្លារ

១៣-លោកវេជ្ជបណ្ឌិត	ស៊ូ	សុខុន	សប្បុរសជននៅទីក្រុងភ្នំពេញ	ថវិកាចំនួន ១៣.៤០០ ដុល្លារ
១៤-លោក	គីវខ្មែង	មយូរ៉ា	សប្បុរសជននៅទីក្រុងភ្នំពេញ	ថវិកាចំនួន ១៩.៥០០ ដុល្លារ
១៥-លោក	ត	ទុល	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១៥.០០០ ដុល្លារ
១៦-លោក	នួន	សុផាត	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.៥០០ ដុល្លារ

ខ_មេដាយគ្រាក់ស្ថាបនាជាតិ :

១-ព្រះតេជគុណ	អ៊ី	គា	គ្រូសូត្រស្តាំ *វត្តប្រាសាទមង្គល*	បច្ច័យចំនួន ៦.៥០០ ដុល្លារ
២-ឧបាសក	ហេង	ឈន	សប្បុរសជននៅខេត្តតាកែវ	ថវិកា ចំនួន ៧.០០០ ដុល្លារ
៣-ឧបាសក	ឯក	ឈុប	សប្បុរសជននៅខេត្តតាកែវ	ថវិកា ចំនួន ៧.០០០ ដុល្លារ
៤-ឧបាសក	អ៊ូ	សន	សប្បុរសជននៅខេត្តតាកែវ	ថវិកា ចំនួន ៦.០០០ ដុល្លារ
៥-លោក	ជុំ	ឈឿង	សប្បុរសជននៅក្រុងភ្នំពេញ	ថវិកា ចំនួន ៦.០០០ ដុល្លារ
៦-លោក	សំ	ហឿក	សប្បុរសជននៅខេត្តតាកែវ	ថវិកា ចំនួន ៦.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ...... សហវ.ប្រក. រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០០៧

លិខិតចូល
ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ2007

ប្រកាស
ស្តីពី
ការកំណត់មូលដ្ឋានគិតអាករពិសេសលើទំនិញមួយចំនួនដែលផលិតក្នុងស្រុក

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ និងព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញប្រកាសលេខ ១១៣៣ សហវ.ពដ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការណែនាំអនុវត្តការប្រមូលអាករពិសេសលើទំនិញ និងសេវាមួយចំនួន
- យោងតាមការចាំបាច់នៃការងារគ្រប់គ្រងប្រមូលពន្ធរបស់នាយកដ្ឋានពន្ធដារ ។

សម្រេច :

ប្រការ ១.- ថ្លៃលក់ចេញពីរោងចក្រកត់ត្រាក្នុងវិក្កយបត្រ ដែលជាមូលដ្ឋានសម្រាប់គិតអាករពិសេសលើទំនិញមួយចំនួនដែលផលិតក្នុងស្រុក ដូចមានចែងក្នុងមាត្រា ៨៥ នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវបានកំណត់ស្មើនឹង ៦៥ ភាគរយ នៃថ្លៃផ្គត់ផ្គង់មិនរួមបញ្ចូលអាករលើតម្លៃបន្ថែម ដែលបានកត់ត្រាក្នុងវិក្កយបត្រឱ្យទៅអតិថិជន ដោយមិនគិតអំពីការបញ្ចុះថ្លៃផ្សេងៗឡើយ ។

ប្រការ ២.- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣.- ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៧ តទៅ ។/

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល :
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០០៩......សហវ....ឧហ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០០៧

លិខិតចូល
ថ្ងៃទី...ខែ...ឆ្នាំ20...

សេចក្តីជូនដំណឹង

ស្តីពីការផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណ ប្រកបសេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជូនដំណឹងជាថ្មីម្តងទៀតដល់ លោក លោកស្រី ដែលកំពុងប្រកបសេវាកម្មវាយតំលៃ ឬសេវាកម្មទិញ លក់ ជួល អចលនវត្ថុ នៅព្រះរាជាណាចក្រកម្ពុជាទាំងអស់ អោយបានជ្រាបថា កន្លងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើការចុះផ្សាយតាមរយៈសារពត៌មានក្នុងស្រុកដោយអញ្ជើញ លោក លោកស្រី ដែលបាននិងកំពុងប្រកបសេវាកម្មជាក្រុមហ៊ុនវាយតំលៃអចលនវត្ថុ និង ក្រុមហ៊ុនអចលនវត្ថុ (ទិញ លក់ ជួល អចលនវត្ថុ)ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មកដាក់ពាក្យសុំវិញ្ញាបនបត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណ ដើម្បីប្រកបសេវាកម្មជាក្រុមហ៊ុនវាយតំលៃ ឬជាក្រុមហ៊ុនអចលនវត្ថុ ។ រហូតមកដល់ពេលនេះ យើងពិនិត្យឃើញថា មានក្រុមហ៊ុនជាច្រើនបានរួសរាន់មកដាក់ពាក្យរួចរាល់ហើយ ប៉ុន្តែក៏នៅមានក្រុមហ៊ុនមួយចំនួនតូច ដែលមិនទាន់បានមកដាក់ពាក្យ ។ ដូច្នេះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមអញ្ជើញ លោក លោកស្រី ដែលកំពុងប្រកបសេវាកម្មខាងលើ ហើយមិនទាន់បានមកដាក់ពាក្យ មេត្តារួសរាន់មកដាក់ពាក្យអោយបានមុនដំណាច់ **ខែ ឧសភា ឆ្នាំ ២០០៧** នៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ) នៅរៀងរាល់ម៉ោងធ្វើការ ។ ពត៌មានបន្ថែមសូមទំនាក់ទំនងមកនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

សំគាល់: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងអនុវត្តទៅតាមផ្លូវច្បាប់ចំពោះអ្នកប្រកបសេវាកម្មវាយតំលៃ និង សេវាកម្មអចលនវត្ថុទាំងឡាយណាដែលពុំព្រមអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសស្តីពីការផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈ និង អាជ្ញាប័ណ្ណ លេខ ១៤២ សហវ. ប្រក. ឧហ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ទូរស័ព្ទទំនាក់ទំនង:

- ០២៣ ៤២៧ ៩៣៥
- ០១២ ៤៣០ ០០៩
- ០១២ ២០០ ០៦១
- ០១១ ៨៦៨ ៩៦១

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

❀❀❀❀❀❀❀

ក្រសួងអប់រំ យុវជន និង កីឡា

លេខៈ ៦០៦ អយក.ប្រក

ប្រ កា ស

ស្តីពីការបើកអនុវិទ្យាល័យ " **រំលេច** "

ស្ថិតនៅក្នុង ឃុំ រំលេច ស្រុក ស៊ីធរកណ្តាល ខេត្ត ព្រៃវែង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
